# ក្រឹត្យច្បាប់

## ស្ដីពី

# ការគ្រប់គ្រងវិស័យជលផល

๑๒๘๖

**ក្រុមប្រឹក្សារដ្ឋ**

**ក្រឹត្យ-ច្បាប់/៣៣ ក្រ.ច/៩ មីនា ១៩៨៧/ស្តីពីការគ្រប់គ្រងវិស័យជលផល**

ក្រុមប្រឹក្សារដ្ឋមន្ត្រីនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំរដ្ឋសភា និងក្រុមប្រឹក្សារដ្ឋនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៤ ក្រ ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ១៩៨២
- បានឃើញច្បាប់ស្តីអំពីអង្គការចាត់តាំង និងសកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រីនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៣ ក្រ ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ១៩៨២
- បានឃើញក្រឹត្យ-ច្បាប់លេខ ០៧ ក្រ.ច ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ១៩៨២ ស្តីពីសមត្ថកិច្ច និងនីតិវិធីនៃការធ្វើច្បាប់និងបទបញ្ជា
- បានឃើញក្រឹត្យ-ច្បាប់លេខ ២២ ក្រ.ច ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ១៩៨៥ ស្តីពីពន្ធប៉ាតង់
- បានឃើញក្រឹត្យ-ច្បាប់លេខ ២៣ ក្រ.ច ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ១៩៨៥ ស្តីពីពន្ធអាជីវកម្ម
- តាមសំណើរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី

**សំរេច**

**ជំពូកទី១: បទប្បញ្ញត្តិទូទៅ**

**មាត្រា១:** ធនធានជលផលមានសត្វ និងរុក្ខជាតិមានជីវិតដែលកកើត និងរស់នៅក្នុងដែននេសាទ។

ដែននេសាទមាន:

១. ដែននេសាទទឹកសាប: ទន្លេ ដៃទន្លេ បឹង ព្រែក ស្ទឹង អូរ នាទីព្រៃលិចទឹក ឬប្រឡាយ ត្រពាំង វណ្ណៅ ដែលមានប្រភពទឹកពីទន្លេ ដៃទន្លេ បឹង ព្រែក ស្ទឹង។

២. ដែននេសាទសមុទ្រ: លាតសន្ធឹងពីតំបន់ឆ្នេរសមុទ្ររហូតដល់ព្រំប្រទល់ខាងក្រៅ នៃដែនសមុទ្រសេដ្ឋកិច្ចផ្តាច់មុខរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជា។

ដែននេសាទគឺជាកម្មសិទ្ធិរបស់រដ្ឋ។

**មាត្រា២:** ដែននេសាទទឹកសាបចែកជា:

១. ដែននេសាទរៀបដោយពួក

២. ដែននេសាទដែលត្រូវការពារ

**មាត្រា៣:** ដែននេសាទរៀបដោយពួកមានបីប្រភេទ:

១. កន្លែងនេសាទដែលត្រូវកំណត់ជាឡូត៍នេសាទ ហើយដែលទុកសំរាប់តែអង្គភាពនេសាទរដ្ឋ និងក្រុមសាមគ្គីនេសាទដែលបានទទួលសិទ្ធិធ្វើអាជីវកម្មនេសាទ។

២. កន្លែងនេសាទបំរុងទុកសម្រាប់អោយមច្ឆាជាតិពងកូន ឬធ្វើការពិសោធន៍ស្រាវជ្រាវវិទ្យាសាស្ត្របច្ចេកទេសនេសាទ។

៣. នាទីព្រៃលិចទឹកដោយរាប់បញ្ចូលជួរព្រៃទាំងអស់ដែលលិចទឹកនៅរដូវទឹកឡើង និងដែលជាជំរកចាំបាច់របស់មច្ឆាជាតិក្នុងការស្វែងរកចំណី និងកន្លែងពងកូន។

ព្រំប្រទល់នៃនាទីឡូត៍នេសាទ កន្លែងនេសាទបំរុងទុក និងនាទីព្រៃលិចទឹកត្រូវកំណត់ដោយប្រកាសរបស់ក្រសួងកសិកម្ម។

**មាត្រា៤:** ដែននេសាទដែលត្រូវការពារ គឺកន្លែងនេសាទទាំងឡាយដែលពុំមានចែងក្នុងប្រភេទណាមួយនៃដែននេសាទរៀបដោយពួកដែលចែងក្នុងមាត្រា ៣។

**មាត្រា៥:** អង្គភាពរដ្ឋ ក្រុមសាមគ្គី ឬអ្នកនេសាទទាំងអស់ដែលធ្វើអាជីវកម្មនេសាទក្នុងដែននេសាទទឹកសាប ឬសមុទ្រត្រូវមានកាតព្វកិច្ចបង់វិភាគទាននេសាទជូនរដ្ឋ តាមការកំណត់របស់រដ្ឋ និងតាមកិច្ចសន្យាលើកលែងតែអ្នកនេសាទជាលក្ខណៈគ្រួសារ។

- អង្គការពន្ធ និងអង្គការជលផលត្រូវពិនិត្យពិភាក្សាឯកភាពគ្នាក្នុងការកំណត់ផលរបរ និងប្រាក់ចំណេញដើម្បីកំណត់ចំនួនប្រាក់ពន្ធប៉ាតង់តាមតារាងកំណត់ប្រាក់ពន្ធប៉ាតង់ដូចមានចែងក្នុងក្រឹត្យ-ច្បាប់លេខ ២២ ក្រ.ច ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ១៩៨៥ និងចំនួនប្រាក់ពន្ធអាជីវកម្មតាមអត្រាកំណត់ដូចមានចែងក្នុងក្រឹត្យ-ច្បាប់លេខ ២៣ ក្រ.ច ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ១៩៨៥។

**មាត្រា៦:** ការអនុញ្ញាតអោយធ្វើអាជីវកម្មក្នុងដែននេសាទ វារីវប្បកម្មច្នៃផលនេសាទ និងការអនុញ្ញាតពិសេសត្រូវកំណត់ដោយប្រកាសរបស់ក្រសួងកសិកម្ម។

ការបែងចែកឡូត៍នេសាទ ការបង់វិភាគទាននេសាទ និងការដឹកនាំផលនេសាទត្រូវកំណត់ដោយ អនុក្រឹត្យ។

## ជំពូកទី២: ការធ្វើអាជីវកម្មក្នុងដែននេសាទទឹកសាប ចរិប្បកម្ម និងការច្នៃផល នេសាទទឹកសាប

**មាត្រា៧:** ការធ្វើអាជីវកម្មនេសាទគ្រប់ប្រភេទក្នុងដែននេសាទរៀបដោយពួក ដោយគ្មានលិខិត អនុញ្ញាត និងមិនត្រឹមត្រូវតាមបទបញ្ជាត្រូវហាមឃាត់។

ការធ្វើអាជីវកម្មក្នុងឡូត៍នេសាទអាចប្រព្រឹត្តទៅបាន លុះត្រាតែមានលិខិតអនុញ្ញាតហើយត្រូវធ្វើតែនៅក្នុងរយៈពេលបើកនេសាទ ដែលមានកំណត់បញ្ជាក់ក្នុងសៀវភៅបន្ទុក ឬលិខិតអនុញ្ញាតអោយធ្វើ នេសាទ។

**មាត្រា៨:** អង្គភាពរដ្ឋ ឬក្រុមសាមគ្គីនេសាទដែលបានទទួលសិទ្ធិធ្វើអាជីវកម្មនេសាទក្នុងឡូត៍នេសាទត្រូវគោរពដាច់ខាតតាមសៀវភៅបន្ទុក ឬលិខិតអនុញ្ញាតអោយធ្វើនេសាទ និងត្រូវកត់ត្រាក្នុងសៀវភៅស្ថិតិអោយបានទៀងទាត់រៀងរាល់ថ្ងៃនូវផលនេសាទដែលចាប់បាន។

សៀវភៅស្ថិតិខាងលើនេះត្រូវមានចុះហត្ថលេខាបញ្ជាក់ពីអង្គការជលផលខេត្ត ក្រុងរៀងរាល់ខែ។

**មាត្រា៩:** ក្នុងរយៈពេលបើកនេសាទ ទីតាំងនេសាទទាំងឡាយដែលធ្វើកាត់ផ្លូវទឹកក្នុងឡូត៍នេសាទត្រូវបើកមុខទឹកសំរាប់អោយជនយានគ្រប់ប្រភេទអាចធ្វើចរាចរបាន ហើយមិនត្រូវធ្វើអោយទឹកចាល់នៅមុខរបាំងទេ។

ក្នុងរយៈពេលបិទនេសាទត្រូវរុះរើ និងដកចេញនូវទីតាំងនេសាទទាំងឡាយ ដែលនៅក្នុងឡូត៍នេសាទអោយបានមុនថ្ងៃទី១៥ ខែមិថុនា ចំពោះតំបន់ដែលស្ថិតនៅខាងជើងខ្សែស្របទន្លេចតុមុខ និងមុនថ្ងៃទី ១៥ ខែកក្កដា ចំពោះតំបន់ដែលស្ថិតនៅខាងត្បូងខ្សែស្របទន្លេចតុមុខ។

**មាត្រា១០:** ការធ្វើនេសាទក្នុងដែននេសាទដែលត្រូវការពារ អាចអនុញ្ញាតអោយធ្វើបានតែក្នុងលក្ខណៈ ២យ៉ាងគឺ:

- ការធ្វើនេសាទជាលក្ខណៈគ្រួសារ
- ការធ្វើនេសាទជាលក្ខណៈសិប្បកម្ម

ឯការធ្វើនេសាទជាលក្ខណៈឧស្សាហកម្មត្រូវហាមឃាត់។

ឧបករណ៍នេសាទជាលក្ខណៈគ្រួសារ សិប្បកម្ម ឧស្សាហកម្មត្រូវកំណត់ដោយប្រកាសរបស់ក្រសួង កសិកម្ម។

**មាត្រា១១:** ការធ្វើនេសាទជាលក្ខណៈគ្រួសារ គឺគ្រាន់តែសម្រាប់ផ្គត់ផ្គង់ផលនេសាទដល់គ្រួសារប៉ុណ្ណោះ ហើយអាចប្រព្រឹត្តទៅបានគ្រប់ពេលវេលានៅក្នុងដែននេសាទ ដែលត្រូវការពារនិងក្នុងរយៈពេលបិទនៅក្នុងឡូត៍នេសាទ។

**មាត្រា១២:** ការធ្វើនេសាទជាលក្ខណៈសិប្បកម្មក្នុងដែននេសាទ ដែលត្រូវការពារអាចប្រព្រឹត្តទៅបានលុះត្រាតែ:

ក. មានលិខិតអនុញ្ញាត

ខ. ធ្វើនៅក្នុងរយៈពេលបើកនេសាទគឺពីថ្ងៃទី១ ខែតុលា ដល់ថ្ងៃទី៣១ ខែឧសភា ចំពោះដែននេសាទដែលស្ថិតនៅខាងជើងខ្សែស្របទន្លេចតុម្មុខ និងពីថ្ងៃទី១ ខែវិច្ឆិកា ដល់ថ្ងៃទី៣០ ខែមិថុនា ចំពោះដែននេសាទដែលស្ថិតនៅខាងត្បូងខ្សែស្របទន្លេចតុម្មុខ។

គ. គោរពតាមបទបញ្ជាដែលមានចែងក្នុងលិខិតអនុញ្ញាតអោយធ្វើនេសាទ។

ឃ. កត់ត្រាក្នុងសៀវភៅស្ថិតិអោយបានទៀតទាត់រៀងរាល់ថ្ងៃ នូវផលនេសាទដែលចាប់បានសៀវភៅស្ថិតិនេះត្រូវមានចុះហត្ថលេខាបញ្ជាក់ពីអង្គការជលផលខេត្ត ក្រុងរៀងរាល់ខែ។

**មាត្រា១៣:** ត្រូវហាមឃាត់ជាដាច់ខាតគ្រប់ពេលវេលា និងគ្រប់ទីកន្លែងនូវការធ្វើនេសាទក្នុងដែននេសាទដែលត្រូវការពារ ដោយប្រើឧបករណ៍គ្រប់ប្រភេទរួមផ្សំដោយរបាំងព្រួលដែលមានបណ្តោយ លើសពី ៥០ម ឬលាតសន្ធឹងលើសពី ២ភាគ៣ នៃទទឹងមុខទឹក ឬធ្វើអោយរាំងស្ទះផ្លូវជលយានគ្រប់ ប្រភេទ។

**មាត្រា១៤:** ផុយនឹងបទប្បញ្ញត្តិដែលមានចែងក្នុងមាត្រា ១៣ការធ្វើនេសាទក្នុងដែននេសាទ ដែលត្រូវការពារដោយ លប ណ ឬរ៉ាវដែលមានប្រវែងតិចជាង ៥០០មនៅក្នុងបឹងទន្លេសាប អាចអនុញ្ញាតអោយធ្វើបានពីថ្ងៃទី១ ខែកុម្ភៈ ដល់ថ្ងៃទី២០ ខែឧសភា ក្នុងកន្លែងដែលមានចំងាយយ៉ាងច្រើនបំផុត ៤គ.មពីមាត់ច្រាំង និងក្នុងតំបន់ដែលកំណត់ដោយប្រកាសរបស់ក្រសួងកសិកម្ម។

ការបោះទីតាំង លប ណ ឬរ៉ាវនេះមិនត្រូវធ្វើអោយរាំងស្ទះផ្លូវជលយានគ្រប់ប្រភេទទេ។

ទីតាំង លប ណ ឬរ៉ាវទាំងឡាយត្រូវដកចេញអោយអស់មុនថ្ងៃទី៣១ ខែឧសភា ដាច់ខាត។

**មាត្រា១៥:** ការធ្វើនេសាទជាលក្ខណៈសិប្បកម្មដោយអួន ទោះជាមួយវង់ ឬច្រើនវង់តភ្ជាប់គ្នាក៏ដោយ អាចប្រព្រឹត្តទៅបានលុះត្រាតែអួននោះមានបណ្តោយតិចជាង:

- ៤០០ម ចំពោះដែននេសាទដែលត្រូវការពារនៅក្រៅបឹងទន្លេសាប ។

- ១.០០០ម ចំពោះដែននេសាតដែលត្រូវការពារនៅក្នុងបឹងទន្លេសាប ។

មិនអនុញ្ញាតអោយធ្វើនេសាទជាលក្ខណៈសិប្បកម្មដោយអួននៅក្នុងកន្លែងនេសាទ ដែលទុកសំរាប់តែប្រជាជនក្នុងកន្លែងនេសាទ ដែលធ្វើអោយរំខានដល់ការធ្វើអាជីវកម្មក្នុងឡូតិ៍នេសាទ និងក្នុងកន្លែងនេសាទដែលមានទម្លាប់ធ្វើអាជីវកម្មនេសាទដោយប្រើឧបករណ៍តូចៗ ។ កន្លែងនេសាទទាំងបីខាងក្រោយនេះត្រូវកំណត់ដោយក្រសួងកសិកម្ម ។

**មាត្រា១៦:** ការធ្វើនេសាទគ្រប់ប្រភេទក្នុងកន្លែងនេសាទបំរុងទុក ឬការធ្វើនេសាទដោយប្រើឧបករណ៍ដាយចាប់ត្រី ឬចាប់បង្កងនៅក្រៅឡូតិ៍ដាយចាប់ត្រី ចាប់បង្កងត្រូវហាមឃាត់ដាច់ខាត លើកលែងតែការស្រាវជ្រាវវិទ្យាសាស្ត្របច្ចេកទេសរបស់នាយកដ្ឋានជលផលដោយមានការអនុញ្ញាតពិសេស ។

**មាត្រា១៧:** ត្រូវហាមឃាត់ជាដាច់ខាត ចំពោះការធ្វើនេសាទគ្រប់ប្រភេទក្នុងដែននេសាទទឹកសាបដោយប្រើឧបករណ៍ហាមឃាត់ដូចខាងក្រោមនេះ:

ក. ខ្សែភ្លើងឆក់ វំសេវ គ្រឿងផ្ទុះ ឬថ្នាំបំពុលគ្រប់ប្រភេទ

ខ.ឧបករណ៍សំរាប់បូម បាច ពង្រីងផ្ទៃកណាមួយនៃដែននេសាទ

គ. សម្រះ ឬមធ្យោបាយផ្សេងទៀតដែលធ្វើអោយត្រីកុំ

ឃ. ច្បូក សាង ឬស្ទូរមផ្សំកែវផ្ទុះ

ង.មង ឬអួនគ្រប់ប្រភេទដែលមានក្រឡាតូចជាង ១,៥សម

ច. មងបោះ មងកាំងឬមងពោះថ្លាន់គ្រប់ប្រភេទ

ឆ. ឧបករណ៍នេសាទគ្រប់ប្រភេទដែលរុញ ឬអូសដោយកំលាំងម៉ាស៊ីន

ជ. ព្រួលគ្រប់ប្រភេទ ដែលមានចន្លោះពីត្រៀមមួយទៅត្រៀមមួយតូចជាង ១,៥សម

ឈ. ខ្សែចងគ្រប់ប្រភេទ និងមធ្យោបាយផ្សេងៗទៀតដែលបង្កលក្ខណៈអោយត្រីផ្អើល

ញ. ទំនប់រួមផ្សំដោយឧបករណ៍នេសាទគ្រប់ប្រភេទ

ដ. ឧបករណ៍នេសាទទំនើប ឬរបៀបនេសាទថ្មី ដែលគ្មានកំណត់ក្នុងប្រកាសរបស់ក្រសួងកសិកម្ម

**មាត្រា១៨:** ត្រូវហាមឃាត់:

ក. ការចាប់ ការលក់ ឬការដឹកនាំកូនត្រី ពងត្រី ក្រពើ ត្រីរាជ ត្រីត្រសក់ ត្រីគល់រាំង

ខ. ការធ្វើទំនប់កាត់បឹង ព្រែក ស្ទឹង ទន្លេ ឬផ្លូវទឹកណាមួយដែលជាដែននេសាទទោះបីជាការធ្វើទំនប់នោះដើម្បីផលប្រយោជន៍កសិកម្មក៏ដោយ។

គ. ការដាំឈូកក្នុងដែននេសាទ

ឃ. ការកាប់ឆ្ការ រាន ឬដុតព្រៃលិចទឹក

ង. ការដឹកនាំ ឬលក់អុសប្រភេទព្រៃលិចទឹក។

គ្រប់ករណីខាងលើនេះអាចប្រព្រឹត្តទៅបានលុះត្រាតែមានការអនុញ្ញាតពិសេស។

**មាត្រា១៩:** ការធ្វើវារីវប្បកម្មក្នុងស្រះ ឬស៊ងដែលមានផ្ទៃក្រឡាសរុបលើសពី ០,៥ហិកតា ឬបែលើស ពី ១៥ម$^{២}$ ការចិញ្ចឹមក្រពើលើសពី ៥ក្បាល អណ្តើកលើសពី ៥០ក្បាល ពស់ថ្លាន់ ឬពស់ត្រីលើសពី ២០ ក្បាល ការបង្កើតទីតាំងលក់ ឬសន្និធិ និងកន្លែងច្នៃប្រឌិតផលនេសាទតាមបែបផែនសិប្បកម្មដែលមានផលនេសាទលើសពី ១តោនក្នុង ១ឆ្នាំ ឬតាមបែបផែនឧស្សាហកម្មអាចប្រព្រឹត្តទៅបានលុះត្រាតែមានលិខិតអនុញ្ញាត។

**មាត្រា២០:** អង្គភាពរដ្ឋ ក្រុមសាមគ្គី ឬជនគ្រប់ប្រភេទដែលបានទទួលលិខិតអនុញ្ញាតអោយប្រកបរបរដែលមានចែងក្នុងមាត្រា ១៩ត្រូវមានសៀវភៅស្ថិតិសំរាប់កត់ត្រា:

- ផ្ទៃក្រឡាស្រះ ស៊ង ឬបែ និងសន្និធិផលនេសាទចិញ្ចឹម ឬប្រស់ចំពោះការធ្វើវារីវប្បកម្ម។
- ការបញ្ចេញ-បញ្ចូល និងសន្និធិរៀងរាល់ថ្ងៃនូវផលនេសាទស្រស់ ឬច្នៃចំពោះការបង្កើតទីតាំងលក់ សន្និធិ និងច្នៃប្រឌិត។

សៀវភៅស្ថិតិនេះត្រូវមានចុះហត្ថលេខាបញ្ជាក់ពីអង្គការជលផលខេត្ត ក្រុងរៀងរាល់ខែ។

**មាត្រា២១:** ការធ្វើសន្និធិផលនេសាទទឹកសាប រស់ ស្រស់ ឬច្នៃក្នុងរយៈពេលបិទនេសាទអាចប្រព្រឹត្តទៅបានលុះត្រាតែមានលិខិតអនុញ្ញាត។

អង្គភាពរដ្ឋ ក្រុមសាមគ្គី ឬអ្នកនេសាទត្រូវធ្វើពាក្យជូនទៅអង្គការជលផលខេត្ត ក្រុងអោយបានយ៉ាងតិច ១៥ថ្ងៃមុនរយៈពេលបិទនេសាទ ដើម្បីអោយអង្គការជលផលខេត្ត ក្រុងផ្ទៀងផ្ទាត់ពីសន្និធិផលនេសាទនោះ។

## ជំពូកទី៣: ការធ្វើអាជីវកម្មនេសាទក្នុងដែននេសាទសមុទ្រ វារីវប្បកម្ម និងការច្នៃផលនេសាទសមុទ្រ

**មាត្រា២២:** ការធ្វើនេសាទគ្រប់ប្រភេទក្នុងដែននេសាទសមុទ្រនៃសាធារណរដ្ឋប្រជាមានិតកម្ពុជាអាចប្រព្រឹត្តទៅបានលុះត្រាតែមានលិខិតអនុញ្ញាត លើកលែងតែការធ្វើនេសាទជាលក្ខណៈគ្រួសារ ។

ឧបករណ៍នេសាទជាលក្ខណៈគ្រួសារ និងឧបករណ៍នេសាទផ្សេងទៀតដែលអនុញ្ញាតអោយប្រើក្នុងដែននេសាទសមុទ្រនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងកសិកម្ម ។

**មាត្រា២៣:** អង្គភាពរដ្ឋ ក្រុមសាមគ្គី ឬអ្នកនេសាទទាំងអស់ដែលប្រើទូក ឬកាណូតនេសាទនៅក្នុងដែននេសាទសមុទ្រត្រូវមានបន្ថែមទៀតនូវ:

- លិខិតអនុញ្ញាតអោយប្រើប្រាស់ទូក ឬកាណូតពីអង្គការជលផល បន្ទាប់ពីបានត្រួតពិនិត្យតាមលក្ខណការណ៍បច្ចេកទេស ។
- លិខិតអនុញ្ញាតពីស្ថាប័ននគរបាល បន្ទាប់ពីបានត្រួតពិនិត្យតាមលក្ខណការណ៍រដ្ឋបាល ។

**មាត្រា២៤:** ការចូលមកធ្វើអាជីវកម្មនេសាទរបស់បរទេសទាំងឡាយនៅក្នុង ដែននេសាទសមុទ្រកម្ពុជាត្រូវមានលិខិតអនុញ្ញាតក្រោយពីមានការយល់ព្រមពីក្រុមប្រឹក្សារដ្ឋមន្ត្រី ។

**មាត្រា២៥:** អ្នកនេសាទទាំងឡាយ ដែលបានទទួលការអនុញ្ញាតអោយធ្វើអាជីវកម្ម ក្នុងដែននេសាទសមុទ្រត្រូវ:

ក. គោរពតាមបទបញ្ជាដែលមានចែងក្នុងលិខិតអនុញ្ញាតអោយធ្វើនេសាទ

ខ. កត់ត្រាក្នុងសៀវភៅស្ថិតិអោយបានទៀតទាត់រៀងរាល់ថ្ងៃនូវផលនេសាទ ដែលចាប់បានហើយត្រូវរាយការណ៍ជូនអង្គការជលផលខេត្ត ក្រុងរៀងរាល់ខែ ។

សៀវភៅស្ថិតិនេះត្រូវមានចុះហត្ថលេខាបញ្ជាក់ពីអង្គការជលផលខេត្ត ក្រុងរៀងរាល់ខែ ។

**មាត្រា២៦:** ការបោះទីតាំងនេសាទ ឬដាក់ឧបករណ៍នេសាទគ្រប់ប្រភេទដែលលាតសន្ធឹងធ្វើអោយរាំងស្ទះផ្លូវជលយានគ្រប់ប្រភេទត្រូវហាមឃាត់ ។

ការបោះទីតាំងនេសាទ ឬដាក់ឧបករណ៍នេសាទគ្រប់ប្រភេទដែលលាតសន្ធឹងទទឹងព្រែក ស្ទឹង ឬផ្លូវទឹកនៃតំបន់ឆ្នេរសមុទ្រ ត្រូវបើកមុខទឹកមួយភាគបី "១ភាគ៣" ឬយ៉ាងតិចបំផុតពីរភាគបី "២ភាគ៣" នៅពេលទឹកនាច ដើម្បីទុកអោយជលយានគ្រប់ប្រភេទអាចធ្វើចរាចរបាន ។

ទីតាំងនេសាទ ឬឧបករណ៍នេសាទគ្រប់ប្រភេទត្រូវរុះរើចេញយ៉ាងយឺតបំផុត ១៥ថ្ងៃក្រោយពីថ្ងៃឈប់នេសាទ ។

**មាត្រា២៧:** ការធ្វើនេសាទត្រីកាម៉ុង "ប្លាធូ" ក្នុងដែននេសាទសមុទ្រក្នុងរយះពេលពងកូនចាប់ពីថ្ងៃទី ១៥ មករា ដល់ថ្ងៃទី៣១ មីនា ត្រូវហាមឃាត់ ។

**មាត្រា២៨:** ការធ្វើនេសាទដោយអួនអូស ក្នុងដែននេសាទសមុទ្រតាមបណ្តោយឆ្នេរដែលស្ថិតនៅក្នុងចន្លោះចាប់ពីមាត់ច្រាំងទៅទល់នឹងខ្សែបន្ទាត់ដែលមានជំរៅទឹក ២០ម ត្រូវហាមឃាត់ជាដាច់ខាតលើកលែងតែមានការអនុញ្ញាតពិសេស តាមសំណើរបស់នាយកដ្ឋានជលផល ដើម្បីធ្វើការពិសោធន៍ស្រាវជ្រាវបច្ចេកទេសវិទ្យាសាស្ត្រនេសាទ ។

**មាត្រា២៩:** ការធ្វើនេសាទក្នុងដែនសមុទ្រនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ដោយប្រើខ្សែភ្លើងឆក់ គ្រឿងផ្ទុះគ្រប់ប្រភេទ ឬឧបករណ៍នេសាទទំនើបៗដែលពុំទាន់បានកំណត់ក្នុងប្រកាស របស់ក្រសួងកសិកម្មត្រូវហាមឃាត់ដាច់ខាត ។

**មាត្រា៣០:** ការធ្វើវារីវប្បកម្មដែលមានផ្ទៃក្រឡាទឹកសរុបលើសពី ០,៥ហិកតា នៅតំបន់ឆ្នេរសមុទ្រ ឬនាទីដែលមានទឹកជោរនាច ឬនៅតំបន់ទឹកភ្លាវ ការបង្កើតទីតាំងលក់ ឬសន្និធិ និងការបង្កើតកន្លែងច្នៃប្រឌិតតាមបែបផែនសិប្បកម្ម ដែលមានផលនេសាទលើសពី ១តោនក្នុង ១ឆ្នាំ ឬតាមបែបផែនឧស្សាហកម្មអាចប្រព្រឹត្តទៅបានលុះត្រាតែ:

ក. មានលិខិតអនុញ្ញាត

ខ. មានសៀវភៅស្ថិតិសំរាប់កត់ត្រា:

- ផ្ទៃក្រឡានៃកន្លែងធ្វើវារីវប្បកម្ម និងសន្និធិផលនេសាទសមុទ្រដែលចិញ្ចឹម ឬប្រស់ចំពោះការធ្វើវារីវប្បកម្ម ។

- ការបញ្ចេញ-បញ្ចូល និងសន្និធិរៀងរាល់ថ្ងៃនូវផលនេសាទសមុទ្រស្រស់ ឬច្នៃចំពោះការបង្កើតទីតាំងលក់សន្និធិ ឬច្នៃប្រឌិត ។

សៀវភៅស្ថិតិនេះត្រូវមានចុះហត្ថលេខាបញ្ជាក់ពីអង្គការជលផលខេត្ត ក្រុងរៀងរាល់ខែ ។

## ជំពូកទី៤

## អង្គការមានសមត្ថកិច្ចដោះស្រាយបទល្មើសជលផល

**មាត្រា៣១:** ការត្រួតពិនិត្យ ស្រាវជ្រាវរកបទល្មើសជលផលជាសមត្ថកិច្ច របស់អង្គការជលផលគ្រប់ថ្នាក់ ។

នាយកដ្ឋានជលផលមានសមត្ថកិច្ចត្រួតពិនិត្យ ស្រាវជ្រាវរកបទល្មើសជលផលទាំងអស់នៅលើទឹកដីនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ។

អង្គការជលផលខេត្ត ក្រុងមានសមត្ថកិច្ចត្រួតពិនិត្យ ស្រាវជ្រាវរកបទល្មើសជលផលនៅក្នុងរង្វង់ខេត្ត ក្រុងរបស់ខ្លួន ។

ដើម្បីអនុវត្តភារកិច្ចខាងលើនេះ កម្មាភិបាល បុគ្គលិកជលផលមានសិទ្ធិដូចតទៅ:

ក. ត្រួតពិនិត្យការធ្វើអាជីវកម្មគ្រប់ប្រភេទក្នុងដែននេសាទ

ខ. ត្រួតពិនិត្យការដឹកនាំផលនេសាទតាមមធ្យោបាយនានា

គ. ត្រួតពិនិត្យកន្លែងច្នៃប្រឌិត ឬសន្និធិ ទីតាំងលក់ផលនេសាទគ្រប់ប្រភេទ និងកន្លែងធ្វើវារីវប្បកម្ម ។

ឃ. ធ្វើកំណត់ហេតុអំពីការត្រួតពិនិត្យ និងដោះស្រាយក្នុងករណីល្មើសច្បាប់ ឬបទបញ្ជាជលផល

ង. ក្នុងករណីចាំបាច់ និងស្របច្បាប់ឃាត់ខ្លួនជនល្មើស និងឃាត់ទុក ឬបំផ្លាញចោលវត្ថុតាង ។

**មាត្រា៣២:** សិទ្ធិដោះស្រាយបទល្មើសជលផលត្រូវកំណត់ដូចតទៅ:

- អង្គការជលផលស្រុកមានសិទ្ធិពិន័យជាប្រាក់រហូតដល់ ២.០០០៖០០ ។
- អង្គការជលផលខេត្ត ក្រុងមានសិទ្ធិពិន័យជាប្រាក់រហូតដល់ ១០.០០០៖០០ ។
- នាយកដ្ឋានជលផលមានសិទ្ធិពិន័យជាប្រាក់ចាប់ពី ១០០៖០០ ឡើងទៅ ។

- ផលនេសាទស្រស់ ឬច្នៃដែលបានឃាត់ទុកពីការប្រព្រឹត្តល្មើស ហើយទុកយូរមិនបានអាចលក់បាន ដោយគ្មានកំណត់ពេលក្រោយពីបានពិភាក្សាឯកភាពគ្នារវាងគណៈកម្មាធិការប្រជាជនបជិវត្ត និងអង្គការជលផល ។

**មាត្រា៣៣ះ** សមត្ថកិច្ចដោះស្រាយបណ្តឹតតវ៉ាអំពីការពិន័យ ឬឃាត់ទុកវត្ថុតាងនៃបទល្មើសជលផល ត្រូវកំណត់ដូចខាងក្រោមះ

- ការតវ៉ាពីសេចក្តីសំរេចអំពីពិន័យ ឬឃាត់ទុកវត្ថុតាងរបស់អង្គការជលផលស្រុកត្រូវអង្គការជលផល ខេត្ត ក្រុងសំរេច ។

- ការតវ៉ាពីសេចក្តីសំរេចអំពីពិន័យ ឬឃាត់ទុកវត្ថុតាងរបស់អង្គការជលផលខេត្ត ក្រុងត្រូវគណៈកម្មាធិការប្រជាជនជិវត្តខេត្ត ក្រុងសំរេចបើមិនស្រេចត្រូវបញ្ជូនសំណុំរឿងទៅតុលាការ ។

- ការតវ៉ាពីសេចក្តីសំរេចរបស់នាយកដ្ឋានជលផលអំពីពិន័យ ឬឃាត់ទុកវត្ថុតាងត្រូវក្រសួងកសិកម្ម សំរេច បើមិនស្រេចត្រូវបញ្ជូនសំណុំរឿងទៅតុលាការ ។

**មាត្រា៣៤ះ** គ្រប់កំណត់ហេតុស្តីពីបទល្មើសជលផល ការដោះស្រាយបទល្មើសជលផល ឬបណ្តឹងតវ៉ាពីដំណោះស្រាយបទល្មើសជលផល ត្រូវចំលងជូនក្រសួងកសិកម្ម "នាយកដ្ឋានជលផល" ជាបន្ទាន់ ។

ក្នុងពេលប្រតិបត្តិការ កម្មាភិបាល និងបុគ្គលិកជលផលត្រូវស្លៀកពាក់ឯកសណ្ឋានពាក់សញ្ញាសំគាល់ដែលកំណត់ដោយក្រសួងកសិកម្ម ។

រដ្ឋអំណាចមូលដ្ឋាននានា កងកម្លាំងប្រដាប់អាវុធត្រូវជួយផ្តល់កម្លាំងក្នុងការត្រួតពិនិត្យបទល្មើសជលផលក្នុងករណីដែលមានការស្នើសុំពីកម្មាភិបាល បុគ្គលិកជលផល ។

រដ្ឋអំណាចមូលដ្ឋាននានា ត្រូវទទួលរក្សាទុកជាបណ្តោះអាសន្ននូវវត្ថុតាងនៃបទល្មើសជលផល ដែលបានឃាត់ទុកបើមានការស្នើសុំពីកម្មាភិបាល បុគ្គលិកជលផល ។

## ជំពូកទី៥ះ ទោសប្បញ្ញត្តិ

**មាត្រា៣៥ះ** ជនណាប្រព្រឹត្តល្មើសនឹងក្រឹត្យ-ច្បាប់នេះត្រូវព្រមាន ពិន័យជាប្រាក់ឃាត់ទុករឹបអូសវត្ថុ តាង ឬដាក់ពន្ធនាគារ យោលទៅតាមបទល្មើសធ្ងន់ ឬស្រាល ។

- ការរឹបអូសវត្ថុតាងជាសមត្ថកិច្ចរបស់តុលាការ

- ប្រាក់ពិន័យត្រូវបានជាប្រយោជន៍ថវិការដ្ឋ ។

**មាត្រា៣៦:** ជនណាដែលបានប្រព្រឹត្តល្មើសនឹងមាត្រា ៨-១១-១២-២០-២១-២៣ និងមាត្រា១៧ ត្រង់ចំណុច ឃ-ច-ញ មាត្រា១៨ ត្រង់ចំណុច ក-ខ-ង មាត្រា២៥ ត្រង់ចំណុច ខ និងមាត្រា៣០ ត្រង់ចំណុច ខ ត្រូវពិន័យជាប្រាក់ពី ១០០៛០០ រហូតដល់ ៥០.០០០៛០០ ។ ក្នុងករណីប្រព្រឹត្តល្មើសនឹងមាត្រា ២១ មាត្រា១២ ត្រង់ចំណុច ខមាត្រា ១៧ត្រង់ចំណុច ឃ-ច-ញ និងមាត្រា១៨ ត្រង់ចំណុច ក-ខ-ង ត្រូវរឹបអូសជាសម្បត្តិរដ្ឋ ឬបំផ្លាញចោលនូវវត្ថុតាងបន្ថែមទៀតលើប្រាក់ពិន័យខាងលើ ។

**មាត្រា៣៧:** ជនណាដែលបានប្រព្រឹត្តល្មើសនឹងមាត្រា ១៧ត្រង់ចំណុច គ មាត្រា ១៨ត្រង់ចំណុច គ ត្រូវពិន័យជាប្រាក់ពី ២០០៛០០ រហូតដល់ ៥០.០០០៛០០ ក្នុង១ហិកតា ឬភាគបែងនៃហិកតាក្នុងករណីប្រព្រឹត្តល្មើសនឹងមាត្រា ១៧ ត្រង់ចំណុច គ មាត្រា ១៨ ត្រង់ចំណុច គ ត្រូវរឹបអូសជាសម្បត្តិរដ្ឋ ឬបំផ្លាញចោលនូវវត្ថុតាងបន្ថែមទៀតលើប្រាក់ពិន័យខាងលើ ។

**មាត្រា៣៨:** ជនណាដែលបានប្រព្រឹត្តល្មើសនឹងមាត្រា ៧-៩-១០-១៣-១៤-១៥-១៦-១៩-២២-២៤-២៦-២៧-២៨-២៩ មាត្រា១៧ ត្រង់ចំណុច ក-ខ-ង-ឆ-ជ-ឈ-ដ មាត្រា២៥ ត្រង់ចំណុច ក និងមាត្រា៣០ត្រង់ចំណុច ក ត្រូវពិន័យជាប្រាក់ពី ៥០០៛០០ រហូតដល់ ១៥០.០០០៛០០ ។ ក្នុងករណីប្រព្រឹត្តល្មើសនឹងមាត្រា ៧-៩-១០-១៣-១៤-១៦-២២-២៤-២៦-២៨-២៩- និងមាត្រា ១៧ត្រង់ចំណុច ក-ខ-ង-ឆ-ជ-ឈ-ដ ត្រូវរឹបអូសជាសម្បត្តិរដ្ឋ ឬបំផ្លាញចោលនូវវត្ថុតាងបន្ថែមទៀតលើប្រាក់ពិន័យខាងលើ ។

**មាត្រា៣៩:** បទល្មើសដែលមានចែងក្នុងមាត្រា ៣៦-៣៧-៣៨ បើប្រព្រឹត្តនៅពេលយប់ ឬកន្លែងនេសាទបំរុងទុក ឬនាទីព្រៃលិចទឹកនឹងត្រូវពិន័យជាប្រាក់ទ្វេមួយជាពី ។ បើការប្រព្រឹត្តនោះចូលក្នុងករណីមិនរាងចាល ឬបង្កឡើងអោយមានអន្តរាយធ្ងន់ធ្ងរត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពី៣ខែដល់ ៣ឆ្នាំបន្ថែមលើប្រាក់ពិន័យ ។

**មាត្រា៤០:** បើជនប្រព្រឹត្តល្មើស មិនព្រមបង់ប្រាក់ពិន័យ ឬមិនព្រមបង់វិភាគទាននេសាទតាមកិច្ចសន្យាត្រូវបញ្ជូនសំណុំរឿងទៅតុលាការ ។

**មាត្រា៤១:** ជនណាដែលបានបិទបាំង ឬការពារអំពើល្មើសគេចបំបាត់ប្រាក់ពិន័យ ប្រាក់ពន្ធ វិភាគទាន នៃសាទ ឬរបស់តាងឆ្លៀតយកមុខងារដើម្បីប្រព្រឹត្តល្មើស ទទួលសំណូកនិងអ្នកសូក ឬអ្នកកណ្ដាលក្នុង បទសូកត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន ។

## ជំពូកទី៦: អវសានប្បញ្ញត្តិ

**មាត្រា៤២:** បទប្បញ្ញត្តិទាំងឡាយដែលផ្ទុយនឹងក្រឹត្យ-ច្បាប់នេះត្រូវទុកជានិរាករណ៍ ។

**មាត្រា៤៣:** ក្រុមប្រឹក្សារដ្ឋមន្ត្រីត្រូវទទួលបន្ទុកអនុវត្តក្រឹត្យ-ច្បាប់នេះ ។

**មាត្រា៤៤:** ក្រឹត្យ-ច្បាប់នេះមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃប្រកាសផ្សាយជាសាធារណៈ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី៩ ខែមីនា ឆ្នាំ១៩៨៧

| | |
|---|---|
| ទទួលបន្ទុកអនុវត្ត | ជ.ក្រុមប្រឹក្សារដ្ឋមន្ត្រី |
| ប្រធានក្រុមប្រឹក្សារដ្ឋមន្ត្រី | ប្រធាន |
| ហត្ថលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| ហ៊ុន សែន | ហេង សំរិន |